# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ឧទ្យានសួនសត្វ ព្រៃការពារ និងសួនរុក្ខជាតិ «ភ្នំតាម៉ៅ»

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២២/១០០៨ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ ស្តីពីការបង្កើតឧទ្យានសួនសត្វ ព្រៃការពារ និងសួនរុក្ខជាតិ «ភ្នំតាម៉ៅ»
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខាប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការរៀបចំឧទ្យានសួនសត្វ ព្រៃការពារ និងសួនរុក្ខជាតិ "ភ្នំតាម៉ៅ" ជាអង្គភាពចំណុះរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា ២.-**

ឧទ្យានសួនសត្វ ព្រៃការពារ និងសួនរុក្ខជាតិ "ភ្នំតាម៉ៅ" មានតួនាទី និងភារកិច្ចដូចតទៅៈ

- រៀបចំផែនការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ឧទ្យានសួនសត្វភ្នំតាម៉ៅ តំបន់ព្រៃការពារសម្រាប់ស្តារលទ្ធភាពសត្វព្រៃភ្នំតាម៉ៅ និងតំបន់សួនរុក្ខជាតិឈើប្រណិតភ្នំតាម៉ៅដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ
- គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ព្រៃឈើ និងសត្វព្រៃ
- អភិវឌ្ឍន៍សួនរុក្ខជាតិសាស្ត្រដែលមានពូជឈើប្រណិត និងមានតម្លៃសេដ្ឋកិច្ចខ្ពស់
- អភិវឌ្ឍន៍ជាតំបន់គោលដៅទេសចរណ៍ធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្ត្រ
- ផ្តល់ការថែរក្សា សង្គ្រោះ ព្យាបាល និងស្តារលទ្ធភាពសត្វព្រៃ
- ផ្តល់សេវាកម្មបច្ចេកទេសលើការចិញ្ចឹម និងបង្កាត់ពូជសត្វព្រៃនៅក្នុងសួនសត្វ កសិដ្ឋានចិញ្ចឹមសត្វព្រៃ និងសត្វព្រៃដែលចិញ្ចឹមជាលក្ខណៈគ្រួសារ
- ធ្វើវិបុលកម្មសត្វព្រៃប្រភេទមានដោយកម្រ និងជិតផុតពូជ
- គាំទ្រការសិក្សាស្រាវជ្រាវលក្ខណៈវិទ្យាសាស្ត្រសត្វព្រៃគ្រប់ប្រភេទ ប្រមូលទិន្នន័យ និងផលិតឯកសារវិទ្យាសាស្ត្រពាក់ព័ន្ធនឹងការចិញ្ចឹម សង្គ្រោះ ព្យាបាល ថែទាំ បង្កាត់ពូជ និងដោះលែងសត្វព្រៃទៅក្នុងព្រៃធម្មជាតិ
- អភិវឌ្ឍន៍ជាមូលដ្ឋានសម្រាប់ការសិក្សាស្រាវជ្រាវ អប់រំផ្សព្វផ្សាយអន្តរអំពើរវាងមនុស្ស-សត្វព្រៃ និងព្រៃឈើ
- បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងដីព្រៃឈើ
- រៀបចំបញ្ចូលកម្មវិធីអប់រំនិងផ្សព្វផ្សាយអំពីការអភិរក្សនិងគ្រប់គ្រងប្រភេទសត្វព្រៃនិងរុក្ខជាតិព្រៃសំខាន់ៗដល់ភ្ញៀវទេសចរណ៍ដែលចូលទស្សនានៅក្នុងតំបន់ឧទ្យានសួនសត្វ ព្រៃការពារ និងសួនរុក្ខជាតិ"ភ្នំតាម៉ៅ"
- បង្កើត និងគ្រប់គ្រងបណ្តាញទំនាក់ទំនងជាមួយបណ្តាសួនសត្វនានានៅក្នុង និងក្រៅប្រទេស
- បង្កើនគម្របបៃតង និងបង្កើនសោភ័ណភាពក្នុងតំបន់តាមរយៈការដាំដើមឈើ និងរុក្ខជាតិ
- ដាំ និងថែទាំពូជឈើប្រណិត និងពូជរុក្ខជាតិព្រៃមានតម្លៃសេដ្ឋកិច្ច វេជ្ជសាស្ត្រ សង្គម និងវប្បធម៌
- លើកកម្ពស់ការថែរក្សាធនធានសេនេទិចរុក្ខជាតិ-សត្វព្រៃ និងការអភិវឌ្ឍធនធានធម្មជាតិប្រកបដោយនិរន្តរភាព
- រៀបចំអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវ ភ្លើងបំភ្លឺ អាងស្តុកទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹក) ធ្វើរបង ឬប្រឡាយព័ទ្ធជុំវិញតំបន់ឧទ្យានសួនសត្វ ព្រៃការពារ និងសួនរុក្ខជាតិ "ភ្នំតាម៉ៅ"
- រៀបចំយន្តការប្រមូលចំណូលពីសេវាកម្មទេសចរណ៍ ដើម្បីចូលរួមទ្រទ្រង់សកម្មភាពគ្រប់គ្រងឧទ្យានសួនសត្វ ព្រៃការពារ និងសួនរុក្ខជាតិ "ភ្នំតាម៉ៅ"
- ទំនាក់ទំនង សហការ និងសម្របសម្រួលការងារជាមួយស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិនានាដើម្បីស្វែងរកឱកាសសម្រាប់ដំណើរការការងារដាំស្តារព្រៃឈើ អភិវឌ្ឍន៍សួនរុក្ខជាតិ និងការធ្វើវិបុលកម្ម

ចិញ្ចឹម សង្គ្រោះ ព្យាបាល ថែទាំ ការដោះលែងសត្វព្រៃទៅក្នុងព្រៃធម្មជាតិ និងការបង្កាត់ពូជសត្វព្រៃគ្រប់ប្រភេទទាំងសត្វព្រៃក្នុងស្រុក និងសត្វព្រៃនាំចូលពីក្រៅប្រទេស

- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានរដ្ឋបាលព្រៃឈើប្រគល់ឱ្យ។

**មាត្រា ៣.-**

ឧទ្យានសួនសត្វ ព្រៃការពារ និងសួនរុក្ខជាតិ "ភ្នំតាម៉ៅ" ដឹកនាំដោយប្រធានឧទ្យានមួយរូបថ្នាក់ស្មើប្រធាននាយកដ្ឋាន និងអនុប្រធានឧទ្យានមួយចំនួនថ្នាក់ស្មើអនុប្រធាននាយកដ្ឋាន អនុលោមតាមបទប្បញ្ញត្តិដែលមានជាធរមាន។

**មាត្រា ៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឧទ្យានសួនសត្វ ព្រៃការពារ និងសួនរុក្ខជាតិ "ភ្នំតាម៉ៅ" ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តតាកែវ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១១រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៦
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ